នឹងផ្លែផ្កាក់របស់អ្នកស្រុកពិតប្រាកដ ។

វីឯពួកអ្នកស្រុក ប្រឹងដេញតាមនាយព្រឹលប្រាំពីរប្រាំបីស្រែនៅ តែមិនទាន់ ក៏នាំគ្នាឈប់ដេញដើរត្រឡប់មកផ្ទះវិញទាំងចងគំនុំអាឃាតព្យាបាទ ។

នាយព្រឹល ក្រោយពីដឹងថាពួកអ្នកស្រុកត្រឡប់ទៅ ក្រោយវិញផុតគ្រោះថ្នាក់ហើយ អ្នកក៏ខំទប់អាត្មា ដើរផងវារផង សំដៅទៅផ្ទះយ៉ាងទុព្វលភាព ។

* *
*



## ~៥~

## ស្នេហាខ្វះថ្លៃផុតទូ

បានដល់ភ្នំពេញភ្លេចស្រុកស្រែ ភ្លេចឪភ្លេចម៉ែភ្លេចសង្សា
អាងប្រាក់មួយហ្វឹនចាយហ៊ុហា លេងស្រីពេស្យាផ្សារស៊ីឡូប ។
ដល់ចោរលួចលុយខ្វះថ្លៃផុង ចិនទារឡុងៗញ៉រទត្រិប
ប៉ូលិសអូសកចូលបកក្រិប ភិតភ័យស្ទើរស្លាប់បន់ម៉ែជួយ ។

ព្រឹកស្អែកឡើង ដំណឹងចោរលបឡើងផ្ទះមេស្រុក ក៏លេចឮខ្ចរខ្ចាយទាំងស្រុក ។ លោកមន្ត្រីប្រចាំឃុំបានបិទប្រកាស ហាមប្រាមដល់កូនស្រុក ឱ្យរៀបចំធ្វើរបងស្រាស់បន្លារៀងរាល់ ផ្ទះ ខ្លាចក្រែងមានចោរកួញលបឡើងទៀត ដោយគ្មានអ្នកណាម្នាក់ចាប់ភ្លឹកនឹកសង្ស័យថានាយព្រឹលឡើយ ។ មានតែអាអន្ទិតសនទេដឹងជាក់ថា នាយព្រឹលតែនាយមិនចេញស្តីដោយគុំទុកក្នុងចិត្តថា ថ្ងៃណាមួយនឹងសងសឹកនាយស្រឹកវិញឱ្យទាល់តែបាន។

មួយអាទិត្យកន្លងផុតទៅ នាយព្រឹលក៏បានសះស្បើយជាពីមុខរបួសពកមុខពកមាត់ដូចធម្មតាវិញ ។ មីងព្រាបពូព្រើលទៅស្នើរពាក្យ

ស្តីដណ្តឹងនាងធឿនឱ្យនាយព្រីលក៏បានដូចចិត្តប្រាថ្នា ។ ពូញ៉ោមីង ទ្បឹក យល់ព្រមល្មមចិត្ត គ្មានចាំបាច់សាកសួររកខែឆ្នាំឱ្យគ្រូហោរគន់គូដូច ក្រមុំកម្លោះគេទៀតទេ គាត់គ្រាន់តែបង្គាប់មកខាងប្រុសបន្តិចបន្តួច តាមប្រពៃណី ហើយក៏កំណត់ពេលរៀប មង្គលការឱ្យថ្ងៃចូលស្តីដណ្តឹង នេះរួចស្រេចតែម្តង គឺថ្ងៃ១៣កើត ខែកត្តិកខាងមុខនេះ ។

នាយព្រីល សប្បាយចិត្តណាស់ លែងអៀនខ្មាស់ស្ទុះទៅចាប់ នាងធឿនឱបនាងធឿនឱបមុខមេបាចាស់ទុំទាំងសងខាង ។ មីងទ្បឹក សើចក្អឹកៗ កាច់កកាច់ស្រងដាក់ជន្ទងដោយឃើញកូនប្រុសស្រីចេះ ស្រឡាញ់គ្នា ។

នាយព្រីល ឃើញទឹកមុខឪពុកម្តាយក្មេកក្នុងពេលអនាគត បែប រីករាយញញឹមញញែមមិនប្រកាន់ទោសអូសដំណើរនាយ យើងក៏រឹតតែ បានចិត្ត កៀកដៃនាងធឿនដើរកាត់មុខភ្ញៀវពន្លឺ ចុះជណ្តើរតំរង់ទៅ គុម្ពោតព្រៃក្រោយផ្ទះប្រងើយ ។

-អូនធឿនអ្នា ! អូនធឿនអើយ ... !

-ចាំ ... បងព្រីល !

-នៅតែ១៤ថ្ងៃទៀតទេ យើងទាំងពីរប្រាណបានទៅស្គាល់ ឋាន សួគ៌ដូចអន្ទិតសននាងរ៉នហើយ ...



វាចាចប់ នាយទំពែកក៏យកច្រមុះបោលបុកថ្ពាល់ថ្ពាល់ នាងធឿន ពួស្វរ គឹប ! គឹប ! ខ្សឹត ! ខ្សឹត ! ស្រង់យកជាតិក្លិនប្រហើរយ៉ាង ក្រហល់ក្រហាយ ។

នាងធឿនបានគេបបោសអង្អែល ក៏ធ្វើឫកមាយាដកខ្លី គេចឆ្វេង គេចស្តាំ រើបំរះដូចជាមិនចង់ឱ្យនាយព្រីលលួងលោម តែមិនបានប៉ុន្មាន ក៏ស្រាប់តែដួលផ្ងារស្រទាង ដេកកើយភ្លៅចៅមាណពបើកភ្នែក ព្រឹមៗ និយាយចេញសម្លេងខ្សាវៗ ថា :

-បងព្រីលអើយ ... ! នៅ១៤ថ្ងៃទៀតដូចជាយូរណាស់ ! ចិត្ត អូនចង់ឱ្យម៉ែឪរៀបការឱ្យហើយស្រេចក្នុងថ្ងៃនេះតែម្តង ... បំណាច់នឹង ព្រមឱ្យយើងរៀបការគ្នាជាប្តីប្រពន្ធហើយ ចាំបាច់ទុក ឱ្យយូរថ្ងៃរើសពេល រើសពេលាអីទៀតហ្ន៎ ... ! គិតទៅចាស់ៗ ចំជាស្មុញសាញមែន ... !

-ចិត្តអូននិងបងមិនខុសគ្នាទេ ... ! អំណាចស្រឡាញ់អូន បងចង់តែយកអូនទៅនៅផ្ទះបងក្នុងថ្ងៃនេះផង ហើយបើសិនជាលេប បាន បងលេបអូនទុកក្នុងពោះឥឡូវហ្នឹង ... ព្រលឹងមាសស្នេហ៍ ... !

-បងចេះនិយាយពិរោះមែន ... សំដីបងមួយម៉ាត់ៗ ផ្អែម ដូចទឹកឃ្មុំ ជាតិនេះខ្ញុំសំណាងល្អណាស់ បានប្តីប៉ះលើអ្នកកវីវ៉ោ ហា ...!

នាយព្រីល ត្រូវខ្សល់បញ្ឆោរនាងធឿនសើចបញ្ចេញធ្មេញស្វាញ ។ ដើម្បីឱ្យគេដឹងថាខ្លួនជាអ្នកកំរិវៅហាកាព្យឃ្លោង នាយក៏ខំរកនឹកពាក្យនិយាយយកឃ្លាចុងជូនទាំងត្រដាបត្រដូសថា

-កំណាព្យកាព្យឃ្លោងឃោងអាត្មា អ្នកបានសិក្សាទើបថាត្រូវ.. ខ្លះខំរៀនទាល់តែសក់ស្កូវ តែងកាព្យមិនត្រូវពីព្រោះអី ។ រូបបងក៏មិនមែនចេះឯងស្រាប់ បងរៀនក្បួនច្បាប់តាំងពីបាលី សំស្ក្រិតឡាតាំង ...រូម៉ាំងថ្មី របៀបចែចង់ស្រីចេះបង្ហួរ ! ឡាមួរ១ (L'AMOUR) គឺស្នេហា វរឡា១ (Vorla) ថានុះន៎! ដឺប៊ូ១ Debout ឱ្យក្រោកឈរ កាល់មីន អាស់ប្រូ (Kalmine - Aspro) ថ្នាំឈឺក្បាល ហា ! ហា !

នាយព្រីល និយាយរួចក៏ខំប្រឹងសើចទាំងហត់គឃ្លូរ ពើងទ្រូងទៅមុខ របៀបអ្នកអន្ទ្រើស ។ ឈប់មួយសន្ទុះបាត់ដង្ហក់ នាយព្រីលក៏បែរទៅនិយាយជាមួយនាងធឿនដូចធម្មតាវិញ :

-បងពីរបីថ្ងៃទៀត គិតសុំពុកនិងម៉ែទៅភ្នំពេញទិញឥវ៉ាន់ការហើយ តើអូនចង់ផ្ដែផ្ដាំឱ្យទិញអ្វីទេ ?

-អ៊ូ ! បងទៅភ្នំពេញ ! (នាងធឿនឧទានតិច១ ដោយ ត្រេកអរ) បើបងទៅមិនចាំបាច់ឱ្យអូនផ្ដាំទេ របស់អ្វីក៏ដោយ ឱ្យតែបងទិញផ្ញើសុទ្ធតែពេញចិត្តអូនទាំងអស់ !



-ឥចឹងស្រួលហើយ របស់ណាបងពេញចិត្ត បងស្រឡាញ់ ចាំបងទិញមកផ្ញើ !

-អាព្រីល ! អី...អាព្រីល យី ! អានេះវានាំគ្នាទៅឯណាឥចេះ?

សម្លេងមីងព្រាបស្រែកហៅតាមបង្អួចពីលើផ្ទះ ។ នាយព្រីលប្រញាប់ស្ទុះក្រោកមិម្មា ដឹកដៃនាងធឿន :

-ទៅផ្ទះវិញអូន ! ម៉ែបងគាត់ហៅហើយ ... ខ្ញុំនៅឯណេះ ! ខ្ញុំទៅហើយម៉ែអើយ !

ក្រោយពីនៅអង្គុយលេងសំណេះសំណាលបន្តិចមក ពូព្រីលមីងព្រាបនិងនាយព្រីល ក៏លាម្ចាស់ផ្ទះត្រឡប់ទៅលំនៅ ដ្ឋានខ្លួនវិញ ។

.................................................................

ដូចអស់លោកអ្នកអានជ្រាបស្រាប់ហើយ នូវសណ្ដានចិត្តរបស់នាយព្រីល នាយព្រីលចង់ចេះចង់បានខ្លាំងណាស់ រឿងស្នេហា រឿងរូបថត។ ដូច្នេះកាលបើអស់សង្ឃឹមក្នុងការខ្ចីពីអាអន្ទិតសនហើយមក គាប់ជួនខ្លួនជិតរៀបការទៀត នាយយើងយល់ថាត្រូវតែទៅភ្នំពេញ ទៅនេះប្រយោជន៍ទិញឥវ៉ាន់មករៀបការផង ដើររកទិញរូបថតដូចរបស់អន្ទិតសនផង ។ នាយព្រីលតាំងពីកើតមករហូតសព្វថ្ងៃ មិនដែលបានស្គាល់ទេទីក្រុងភ្នំពេញ ឮតែគេថាធំ ឮតែគេថាសប្បាយដូចឋានសួគ៌ ម្ល៉ោះ

ហើយនាយយើងក៏អរផង ព្រួយផងច្របល់គ្នា ។

ល្ងាចនេះ ក្រោយពីស៊ីបាយទឹកផ្អែតរួចរាល់ នាយព្រីលក៏ ដាច់ចិត្តនិយាយសុំទៅម្ដាយថា :

_ខានស្អែកខ្ញុំសុំម៉ែទៅភ្នំពេញហើយណាម៉ែណា ! ខ្ញុំទៅរកទិញខោអាវ និងឥវ៉ាន់មករៀបការ

_យី ! ឯងគិតទៅភ្នំពេញ ! (មីងព្រាបបើកភ្នែកធំៗ ប៉ុន ពងមាន់) ស្រុកគេធំណាស់វើយ ! តិចលោវង្វេងអត់បាយស្លាប់ អញតាំងពីកើតរហូតដល់ចាស់សក់ស្កូវ ជិតចូលរណ្ដៅស្អែកខានស្អែក អញមិនដែលស្គាល់យ៉ាងម៉េចទេ ! ឯងទៅឯងស្គាល់អ្នកណា ស្រុកគេធំណាស់ កុំទៅអីកូន !

_មិនអីទេម៉ែ ! យើងកើតមកជាកូនខ្មែរត្រូវតែស្គាល់រាជធានីទីក្រុងរបស់ខ្លួន សូម្បីតែអាមេរិកកាំង បារាំង រុស្ស៊ីនៅម្នាក់មួយចំហៀងផែនដី គេនៅមកលេងស្រុកយើងបាន ចុះយើងស្រុកយើងស្រាប់ យើងខ្លាចអី ខ្ញុំទៅមិនមែនអត់គ្នាឯណា ? ខ្ញុំទៅជាមួយអាគុច ដើរឡានបាត់ដំបងភ្នំពេញពីដើមណាម៉ែ ... !

មីងព្រាប ត្រូវកូនបង្ហាញហេតុផលសព្វគ្រប់ គាត់ក៏លែងហ៊ានឃាត់ គ្រាន់តែដាស់តឿនបន្តិចបន្តួចតាមរបៀបចាស់ទុំ :



_អើ ! បើទៅជាមួយអាគុចក៏ទៅចុះម៉ែមិនថាអីទេ តែឯងទៅឱ្យវាសរវើរលមកវិញ ពីព្រោះថ្ងៃការនៅសល់តែជាងដប់ថ្ងៃ ទៀតទេ តើកូនទៅនេះត្រូវការលុយកាក់ស៊ីបាយ ធ្វើសោហ៊ុយ សោជាប៉ុន្មាន ?

នាយព្រីលអង្គុយរាប់ដៃរាប់ជើងមួយសន្ទុះទើបនិយាយទៅកាន់ម្ដាយ :

_មួយម៉ឺនមកបានហើយម៉ែ !

_មួយម៉ឺន ?

មីងព្រាបបញ្ជាក់សំដីកូន ។

_បាទ ! មួយម៉ឺនបានគ្រាន់ម៉ែ បើសល់ខ្ញុំមិនចេះយកមកផ្ទះវិញ? ឬមួយម៉ែឯងមិនចង់ឱ្យខ្ញុំ ?

_មិនមែនឥចឹងទេកូន ! បានជាម៉ែសួរបញ្ជាក់ ព្រោះម៉ែមានលុយវាមិនគ្រប់ ... តែមិនអីទេ ! ស្អែកចាំម៉ែលក់គោមួយនឹមវាគ្រប់ទៅហើយ ! ...

_បាទម៉ែ ... ខ្ញុំអរគុណម៉ែណាស់ ... !

នាយព្រីល ស្ទុះទៅឱបម្ដាយថើបថ្ពាល់ខ្វេងបីបួនខ្សឹតម្ខាង ដោយសេចក្ដីត្រេកអរ ។ មីងព្រាបសប្បាយចិត្តបានកូនប្រុសថើប អង្គុយញញឹមហៀរទឹកមាត់ស្វាកាខ្វាក់ នឹកទៅដល់អតីតភាពកាលគាត់ទើបការ

រូចថ្មីៗ ប្ដីគាត់ក៏ថើបគាត់ញាក់ញីដូចជានាយព្រឹលអញ្ចឹងដែរ ។

ព្រឹកខានស្អែកឡើង នាយព្រឹលនិងនាយគុចក៏បានធ្វើដំណើរតាមរថយន្តឈ្នួលមួយមកភ្នំពេញ ។ ក្នុងឋានៈខ្លួនជាមគ្គុទ្ទេសក៍ នាយគុចនាំនាយព្រឹលទៅជួលសណ្ឋាគារ (Hotel) ម៉្លុំក្បែរផ្សារថ្មីសំណាក់ ដើម្បីឱ្យស្រួលដល់ការដើរលេង ។

នាយព្រឹល ហេតុតែមិនដែលស្គាល់ទីក្រុងធំ ក៏ចេះតែដើរនឹកភ័យៗ និងឡានស៊ីក្លូប្រវាត់ប្រវែង ។ រីឯភ្នែកក៏គយគន់មើលហាងទំនិញធំៗ មើលផ្សារថ្មី មើលផ្លូវថ្នល់ចាក់កៅស៊ូរាបរលើបរលោង ជក់ចិត្តដិតអារម្មណ៍ភ្លេចឃ្លានបាយទឹក ។ ពេលល្ងាចត្រជាក់នាយគុច នាំទៅលេងតាមកន្លែងរមណីយដ្ឋាននានាដូចជា មុខវាំង វិមានឯករាជ្យ, ពិព័រណ៍អចិន្ត្រៃយ៍នៃសង្គមរាស្ត្រនិយម, ស្ពានឆ្លងទន្លេទៅកោះជ្រោយចង្វា ពហុកីឡាដ្ឋានជាតិ (Stade Olympic) វត្តភ្នំ ។ល។ មួយថ្ងៃ ... ពីថ្ងៃ បីថ្ងៃបានកន្លងទៅមុខយ៉ាងរហ័ស នាយព្រឹលឈ្លក់វង្វេងនឹងលំអទីក្រុង ភ្លេចស្រុកស្រែ ភ្លេចឪពុកម្ដាយ គេសប្បាយលែងគិតឃើញអ្វីទាំងអស់ តែចំពោះធៀនគួជណ្ដឹង នាយយើងនៅចាំជាប់ជានិច្ច ។

ម៉ោង៦ហើយ ...

បំផ្លងអគ្គិសនីគ្រប់ដងវិថីក្នុងរាជធានី ឆេះភ្លឺព្រោងព្រាតតាមផ្ទះ



ទំនិញនានាមានដាក់អំពូលពណ៌លឿង ខៀវ ក្រហម ស្វាយចំរុះគ្នា។ មើលទៅសោភ័ណភាពរាត្រី ក្រុងភ្នំពេញពេលនេះប្រៀបបាននឹងឋានកៃឡាស គួរជាទីត្រេកត្រអាលដល់អ្នកសញ្ចរទៅមកគ្រប់ប្រភេទ ។

នាយព្រឹល ឈរពីលើសណ្ឋាគារមើលមកក្រោមបណ្ដែតអារម្មណ៍ឱ្យរសាត់អណ្ដែតទៅតាមសោភ័ណភាពរាត្រីភ្លេចខ្លួនមួយខណៈ ។ នាយគុចនៅដេកលង់ទ្រនេសលើគ្រែមិនទាន់ភ្ញាក់ ដោយមកពីថ្ងៃផឹកសុរាស្រវឹងខ្លាំង ។ ចៅមាណពឈរបណ្ដែត អារម្មណ៍អស់រយៈពេលយូរគ្រែលហើយក៏ដើរចូលទៅខាងក្នុងបន្ទប់វិញ ។

មួយសន្ទុះធំក្រោយមក នាយគុចក៏ភ្ញាក់ពីដេក ។ នាយ បែរទៅនិយាយជាមួយកម្លោះព្រឹល ដែលនៅអង្គុយជិតខ្លួនទាំងអាចម៍ភ្នែកពព្រាកថា :

-អញថ្ងៃម៉ិញផឹកស្រាជ្រុល ស្រវឹងដេកលក់ស្រួលដល់ហើយអាព្រឹល !

-អើ ! អាឯងវាជ្រុលមែន (នាយព្រឹលនិយាយព្រមទាំងសម្លក់នាយគុច) ឱ្យតែហ៊ានផឹកមួយពេលបាយមួយដបរបៀបហ្នឹង ទំរាំដល់ថ្ងៃទៅស្រែវិញប្រហែលខ្វះថ្លៃឡានហើយអញ !

នាយគុចលើកដៃជ្រងសក់សើចហេះ! ហេះ! យកចិត្ត សម្លាញ់:

-កុំនិយាយឥចឹងអាម៉ាក ... ! យ៉ង១ម៉ាឌូ យូរ១មកភ្នំពេញម្តង កុំរៀនកំណាញ់ក្រៅតម្រានាំគេសើច ! ការស៊ីចាយ សប្បាយចិត្តវាជាការធម្មតារបស់អ្នកទេសចរណ៍ទេ ! ថ្ងៃមុនកូនថៅកែឡានគេពីងឱ្យអញជូនមកលេង គេឱ្យស៊ីផឹកច្រើនជាងអាបូនដប់សួនទៅទៀត គេមិនដែលហ៊ានរអ៊ូរទាំដូចអាព្រីលឯងទេ !

នាយព្រីលឮដូច្នោះឡើងជំនោរភ្លែត ភ័យណាស់ខ្លាចគេដៀលថាអ្នកស្រែកំណាញ់មិនហ៊ានស៊ីចាយ ភ័យខ្លាចអន់ថយជាងកូនថៅកែឡាន នាយយើងប្រញាប់ស្រាយទឹកមុខធ្វើជាញញឹមញញែមនិយាយលាងខ្លួនថា :

-អាគុចនិយាយដូចជាមិនធ្លាប់ស្គាល់ចិត្តអញ ! រឿងស៊ី រឿងចាយ អញគ្មានឱ្យចាញ់អាណាមួយរៀលទេ តែដែលអញនិយាយនេះគឺប្រយោជន៍កុំឱ្យឯងខូចសុខភាព ដល់ឯងស្រវឹងខ្លាំងទៅ បានអ្នកណាជូនអញដើរលេង ?

នាយគុចញញឹមប្រឹងបញ្ឆោរថែម :

-អើអញធ្លាប់ដឹងចិត្តឯងវាសៀងឥចឹងដែរ តែខ្លាចដល់ ជិតមានប្រពន្ធកូនទៅ វាប្រែចិត្តគំនិត អារឿងដើរលេងឯងកុំភ័យ យប់នេះចង់ដើរលេងទើសភ្លឺសឹមដេកក៏បានដែរ ... ម៉ុងហ្វូទេ មូសាវ៉ាកញ្ជឹងឡា !



-យើស ! ចេញវប្បធម៌បារាំងផងអាផ្លែ ! ...

នាយព្រីលសើច ដើរទៅយកបារីមកអុជជក់ហើយបន្តវាចាទៀត :

-នែ ! អាគុច ! យើងតាំងពីមកដូចជាមិនទាន់បានទៅលេងកន្លែងណាឱ្យវាសប្បាយជាប់ចិត្តជាប់ថ្លើមសោះ អញឮគេថាភ្នំពេញមានស្រី១ស្អាតណាស់ណាំ ! សុទ្ធតែកូនកាន់យួន កូនចិនកន្លាំងអីផងម៉េចក៏អញដូចជាមិនទាន់បានប្រទះភ្នែកសោះឥចឹង ហើយអារឿងរូបថតក៏ដូចជាមិនទាន់កើតការអី ។

-អាព្រីលឯងចង់លេងស្រីឬ ? ហ៊ឺ ! អានេះចំជាភ្លើមែន ថ្ងៃមុិញពីរបីនាក់ដែលឈរនៅមុខបន្ទប់យើងនុ៎ះអី !

-អ៊ូ ! ពីរបីនាក់ស្លៀកសំពត់ហូលថ្ងៃមុិញស្រីខូច ?

-អើ !

-យី ! អញកុំឱ្យតែបានដឹងអាចោរគេដោត ! អញឃើញវាដែរ អញខំដើរឱនៗកាត់មុខវា នឹកស្មានតែវាប្រពន្ធអស់លោកអ្នក ? ហើយអារឿងរូបថតដូចអញប្រាប់ឯងពីមុន យើងទៅរកទិញនៅហាងឯណាទៅ ?

នាយគុចគ្រវីក្បាល នឹកហួសចិត្តនឹងសំដីភ្លីភ្លើល្ងង់គ្រប់ដប់របស់

មិត្ត :

-រូបថតដូចឯងនិយាយប្រាប់អញហ្នឹង វាមានទាំងអស់៣៦ សន្និក អ្នកស្រុកភ្នំពេញគេហៅថា ហ្វូត្រង់ស៊ីសម៉ានីញ៉ែរ (Photo trente six manières) រូបហ្នឹងគ្រប់ហាងគេអត់ហ៊ានលក់ទេ ព្រោះរាជការគេចាប់ គេថាវាជារូបអាសអាភាស វានាំឱ្យខូចសតិអារម្មណ៍យុវជនយុវនារី តែគិញប៉ូលិសចាប់បាន គឺត្រូវតែជាប់គុក ។

-ចុះម៉េចក៏អាអន្ទិតសនវាមកភ្នំពេញចេះទិញបាន ? វាប្រាប់អញថារូបថតហ្នឹងជាក្បួនស្នេហាទំនើប មើលទៅនាំឱ្យយើងមានសេចក្ដីសុខរីករាយសប្បាយក្នុងចិត្ត ... ?

-ហា ! ហា ! ហា ! (នាយគុចសើច ) ឯងនេះចំជាអាជំឡូងមួលមែន ! អាអន្ទិតសនវាទិញបាន គឺវាទិញតាមពួកផ្ទាដើរលក់វ៉ែនតាស្រោមជើង នាលិកាតាមភោជនីយដ្ឋានធំៗ បើតាមអញដឹង រូបអស់ហ្នឹងវាមិនមែនក្បួនស្នេហាទំនើបដូចអាអន្ទិតសនថាទេ តែបើឯងចង់បានណាស់ស្រេចចិត្តចុះ ចាំថ្ងៃស្អែកអញជួយរកទិញ ។

ការសន្ទនារវាងអ្នកទាំងពីរចេះតែប្រព្រឹត្តទៅក្នុងបរិយាកាសរីករាយរហូតដល់ម៉ោង៧យប់ ទើបគេនាំគ្នាងូតទឹកជំរះរាងកាយ ។ ក្រោយពីបរិភោគអាហាររួចហើយ នាយគុចក៏ នាំនាយព្រើលទៅរក



កំសាន្តជាមួយពួកនារីរាត្រីនៅម្តុំផ្សារស៊ីឡិប

នាយគុចកាលដើមធ្វើព្រូឡានបាត់ដំបង ឱ្យតែត្រូវជើងឡានដេកបេនភ្នំពេញ គេតែងតែមករកកំសាន្តកាយជាមួយពួកនារីទាំងនេះជួនកាលក៏ដេកទាល់តែជិតដល់ពេលឡានចេញ ទើបភ្ញាក់ទៅតាមឡាន។ ញឹកញាប់រាប់មិនអស់ ពួកអ្នកធ្វើការឡានជាមួយគ្នាខឹងក៏នាំគ្នាទៅជំរាបថៅកែៗ ក៏បញ្ឈប់លែងឱ្យធ្វើការតទៅទៀតគឺដើមហេតុដែលបណ្តាលឱ្យនាយគុចខានដើរឡាន ក៏មកតែរឿងដេកជាមួយសាហាយបេនឡានស៊ីឡិបនេះឯង ។

ផ្ទះដែលអ្នកទាំងពីរកំពុងដើរចូលខណៈនេះ គឺជាផ្ទះអ្នកយ៉ែមមេសំផឹងធំ កូនចៅស្រីៗ របស់គាត់តែងហៅគាត់ថាម៉ែយ៉ែមៗ ម៉ែយ៉ែមឬអ្នកយ៉ែម គ្រាន់តែក្រឡេកឃើញនាយគុចភ្លាមក៏ស្គាល់ ស្ទុះមកឱបក្រសោបរាក់ទាក់ដូចសាច់ញាតិឃ្លាតគ្នាម្ភៃឆ្នាំកន្លងមកហើយមិនស្មើ ។

-យី ! បងគុចអើយបងគុច ! បាត់ទៅឯណាកន្លះឆ្នាំហើយមិនដែលឃើញមកអើតសោះ អញ្ជើញអង្គុយៗ បងប្រុសខាងណោះ ! អ្នកយ៉ែមបែរមកគួរសមនឹងនាយព្រើល

នាយព្រើល រវល់តែទាក់ភ្នែកនឹងកូនចៅអ្នកយ៉ែម លុះឮសូរគេអញ្ជើញខ្លួនក៏ភ្ញាក់ដូចគេកន្ត្រាក់ ដាក់គូថអង្គុយផ្ទឹងសម្ងឹងតទៅទៀត ។

-បងរវល់ពេកណាស់អូន បានជាមិនសូវបានមកលេងញឹកញាប់ (នាយគុចនិយាយទៅកាន់អ្នកយ៉ែម) ការរាជការឥឡូវតឹងតែង បងបន្តិចលោកធំប្រើទៅមីស្យុង (Mission) ខេត្តនេះ ខេត្តនោះ ស្ទើរតែរកពេលឈប់សំរាកគ្មានផង ...!

-ឥចឹងហើយបងអើយការរាជការ ... ! (អ្នកយ៉ែមនិយាយ) កាលមុនបងប្រាប់អូនថាជិតឡើងសក្តិបី តើឡើងហើយឬនៅបង ?

-អ៎ូ ! ឡើងជាងបីខែហើយអូន ... !

នាយគុចនិយាយធ្វើវាហី ហាក់ដូចជាគ្មានអើពើនឹងឋានន្តរសក្តិរបស់ខ្លួន ។

នាយព្រីលអង្គុយស្តាប់គេនិយាយគ្នាចេះតែនឹកឆ្ងល់ក្នុងចិត្ត : តើអាគុចវាធ្វើរាជការពីអង្កាល់ ? លោកសក្តិបីហ្នឹងសក្តិបីខាងណា ខាងទាហាន ឬខាងប៉ូលិស ? ទេ ! អាគុចវាព្រូឡានបាត់ដំបងទេតើ ? បើឥចឹងមានតែអានេះភរគេ អូ ! ប្រហែលស្រុកភ្នំពេញគេនិយមនិយាយភរភូតឥចឹងហើយមើលទៅ ? កំពុងតែអង្គុយគិតភ្លេចខ្លួន នាយគុចក៏អូសទាញដៃឱ្យក្រោកឈរ ហើយណែនាំប្រាប់អ្នកយ៉ែមថា :

-នេះសម្លាញ់របស់បង គេធ្វើនាយមេព្រៃនៅស្រុកមោង

-ចំា ! ត្រេកអរណាស់ដែលបានស្គាល់លោក ...



អ្នកយ៉ែមបែរមកចាប់ដៃនាយព្រីលរបៀបបារាំង នាយយើងតាំងពីរកើតមកធ្លាប់តែសំពះ ដល់មកឱ្យចាប់ដៃក៏ច្រឹមច្រំុ វារែកមិនដឹងហុចដៃខាងណាទៅចាប់ ទីបំផុតក៏លូកដៃទាំងពីរទៅចាប់ដៃអ្នកយ៉ែមជាប់ នឹកក្នុងចិត្តថា បើខុសមួយក៏គង់ត្រូវមួយដែរ ។ ពួកកូនសំផឹងនៅក្នុងបន្ទប់ឈប់មើលឃើញថីមេព្រៃភ្លែងក្លាយ ចាប់ដៃម៉ែយ៉ែមរញីរញ៉ូវខុសរបៀបដូចស្គន់ទាញ ក៏នាំគ្នាសើចគឹល ។ អ្នកយ៉ែមខ្លាចថីព្រីលអៀន ប្រញាប់បែរទៅសម្លក់ឱ្យកូនចៅពួកស្រីៗទាំងនោះក៏នាំគ្នាក្តោបមាត់ស្ងាត់ជ្រាបអស់មួយរំពេច ។

នាយគុច នាំនាយព្រីលទៅអង្គុយក្នុងបន្ទប់ពិសេសមួយ ឆ្ងាយពីគេឯង ដើម្បីកុំឱ្យថីមេព្រៃយើងឆ្អើលនឹងចលនាអ៊ូគគ្រុក កគ្រាក់ ។

ក្រោយពីបំប៉នស្រាឆ្នាខ្មៅ នាយព្រីលស្រវឹងស្បែកមុខក្រាស់ដូចស្បែកក្របី ហើយនាយគុចក៏បញ្ឆោរទៅអ្នកយ៉ែមថា :

-មើល៍កូន ! មានអាណាមកថ្មី ក្មេងហើយសាច់សស្អាតទេ យកបីបួនមកឱ្យសម្លាញ់បងវារើស !

-ចា៎ះមានបង ! (អ្នកយ៉ែមឆ្លើយប្រញាប់) បងត្រូវការចិន ខ្មែរ ឬទេ ? ពួកហ្នឹងសុទ្ធតែថ្មីៗទាំងអស់ !

-អើ ! កុំឱ្យចាស់គេ ថ្មីយើងណំា !

នាយគុចសើចមើលមុខសម្លាញ់បន្តិច ទើបនិយាយតថា :

-យកទាំងបីទាំងបួនសាសន៍ហ្នឹងមក សម្លាញ់បងពេញចិត្តមួយណាស្រេចតែវារើស !

-ចំាបង (អ្នកយ៉ែមបែរទៅហៅស្រីៗ) នែ ! អារី ! អារិន ! សុខុម, សាខន, មាំឡា, កាពៅ, ល្អិត មកណេះ !

-ចំា ! ម៉ែ ... !

ពពួកនារីបុប្ផាមាស ឆ្លើយព្រមគ្នាដូចគេណាត់ ហើយក៏រត់ស្រមកជុំវិញខ្លួននាយយើងទាំងពីរនាក់ ។

នាយព្រីលបែបចង់ស្វាងស្រា ក្រឡេកមើលទៅគ្មានទាស់ចិត្តមួយណាសោះ ។ ភ្លើងស្នេហាឡើងកំដៅដល់៩៩អង្សា ផ្ទះអ្នកយ៉ែមក្លាយទៅជាឋានសួគ៌ ស្រីទាំងអស់គឺប្រាកដនាងទេពអប្សរបវរកញ្ញាក្នុងការយល់សប្តិ ។ លែងនឹកនាដល់ឪពុកម្តាយ ស្រែចំការ សង្សារ គោក្របី នាយយើងនឹកឃើញតែម្យ៉ាង គឺពេលនេះគេកំពុងនៅឋានសួគ៌ហែហមទៅដោយហ្វូងនាងទេពអប្សរ ហើយគេចង់នៅរបៀបនេះរហូតទាល់តែស្លាប់ មិនចង់ទៅស្គាល់ក្លិនអាចម៍គោអាចម៍ក្របីក្នុងក្រោលទៀតឡើយ ។

-បងភ្អា ... នៅអង្គុយសម្ងក់សម្ងឹងដល់ណាទៀត យប់ជ្រៅ



ហើយ បងមិនរងាររទេឬ យកអូនទៅគេងឱបលេងមួយយប់ទៅបង អូននឹងធ្វើឱ្យបងមានសេចក្តីសុខទើសភ្លើណា ... !

នាងមួយឈ្មោះសុខុមនិយាយរួច ក៏ស្ទុះទៅថើបឱបរឹត បំពក់ភ្លើងកាមរាគៈនាយព្រីលឱ្យកាន់តែឆេះសន្ធោរព្រឺព្រួច ស្រាវទឹកមាត់កាន់តែខ្លាំងឡើង ។

នាយគុចដឹងអធ្យាស្រ័យរបស់មិត្ត ក៏ងាកមកឱនខ្សឹបដាក់ជិតរន្ធប្រចៀកនាយព្រីលថា :

-យ៉ាងម៉េចសម្លាញ់ ! ឯងពេញចិត្តមួយណា ចាត់ការភ្លាមៗ ទៅយប់កាន់តែជ្រៅហើយ កុំឱ្យខាតពេលវេលាណ៎ា ...!

-អញពេញចិត្តទាំងអស់ !

នាយព្រីលឆ្លើយដោយមិនចាំបាច់គិត ។

-យី ! អាព្រីល ! ឯងនិយាយលេងឬនិយាយមែន ? ស្រីទាំងអស់៧នាក់ក្នុងមួយយប់ឯងស្ទុះរួចឬ ?

នាយគុចប្រឹងសួរបញ្ជាក់ខ្លាចក្រែងសម្លាញ់ស្រវឹងស្រា និយាយមិនដឹងអី តែនាយព្រីលនៅតែឆ្លើយខ្ជឺដដែលថា :

-អញពេញចិត្តទាំងអស់ ! អញស្ទុះរួច !

-អើ ! បើឥចឹងអញសួរថ្លៃគេហើយវើយ !

នាយគិចនិយាយហើយ ក៏ដើរទៅជិតអ្នកយ៉ៃមសួរថ្លៃ :

-ឥឡូវសម្លាញ់បងវាថាវាពេញចិត្តទាំង៧នាក់ហ្នឹង តើអូនឯងគិតប៉ុន្មានថាមកមើល ។

-ចា៎ះ គ្នាឯងមោយចាស់ សុំ៧នាក់ហ្នឹងពីរពាន់បានហើយបង...

-នែ ! សម្លាញ់៧នាក់ហ្នឹង គេគិតក្នុងមួយយប់ពីរពាន់ តើឯងថាយ៉ាងម៉េច ?

បើវាធ្ងន់សោហ៊ុយពេកយកតែពីរនាក់ទៅបានហើយ ។

នាយព្រីលកំពុងលង់ក្នុងសមុទ្រតណ្ហា ក៏ឆ្លើយធ្វើឫកខែងរបៀបលោកធនបតីប្រាក់វាល់បាវថា :

-ពីរពាន់រៀល ! មិនមែនធំប៉ុនក្បាលដំរីទេអាសម្លាញ់ អាឯងហាមាត់សួរអញរបៀបហ្នឹងដូចជាអញវាអន់ពេក វត្ថុអ្វីឱ្យតែអញពេញចិត្តកុំថាឡើយត្រឹមពីរពាន់ ឱ្យពីរពាន់ប្រាំផងក៏អញយកដែរ !

នាយព្រីលនិយាយរួច ក៏ដកកាបូបស្បែកពីហោប៉ៅខោខាងក្រោយហូតក្រដាសប្រាក់ពីរខ្ទាស់បោះទៅឱ្យអ្នកយ៉ៃម ។

-ហក ! យកទៅចុះអ្នកស្រី !

-ចាំ ! ចាំ !

អ្នកយ៉ៃម ស្ទុះទៅរើសក្រដាសប្រាក់មកញាត់ក្នុងហោប៉ៅដៃញ៉រ



ទទ្រើតដោយត្រេកអរ រួចហើយក៏បែរទៅប្រាប់កូនចៅរបស់ខ្លួនថា :

-នែ ! អារី, អារិន, សុខុម, សុខន, ម៉ា, កាពៅ, ល្អិត ! រៀបចំខ្លួនប្រាណទៅ ... ទៅគេងជាមួយលោក

-ចាំម៉ែ !

នារីឆើតឆាយទាំង៧ឆ្លើយព្រមគ្នា ហើយក៏ដើរចេញទៅរៀបចំខ្លួនរៀងៗអាត្មា ។

ប្រហែលដប់នាទីក្រោយមក នារីទាំង៧ក៏ចេញមកវិញ ។ នាយគុចនិងព្រីល និយាយលេងជាមួយអ្នកយ៉ៃមមួយម៉ាត់ពីរ ក៏សូមលានាំនារីរាត្រីទាំង៧ឆ្ពោះមកកាន់សណ្ឋាគាររបស់ខ្លួន ។

អស់រយៈពេលពេញមួយរាត្រី នាយគុចនាយព្រីលឥតបានដេកមួយស្រឡេតសោះ ។ ចំពោះនាយព្រីល រាត្រីនេះគឺជារាត្រីដែលគេបានទទួលសេចក្ដីសុខជាទីបំផុតក្នុងជីវិត ។

ព្រឹកឡើង នាយព្រីលក្រោកពីគ្រែលែងរួច មុខស្លាំងហេវ ក្នុងខ្លួនគ្មានកម្លាំងកំហែង ចំណីចំណុកប៉ះដល់មាត់ល្វីងចត់ទាំងអស់ ។ នាយគុចបានដាស់ឱ្យចុះទៅក្រោមរកស្រស់ស្រូបកាហ្វេ គុយទាវ តែនាយយើងគ្រវីក្បាលបដិសេធ ម្ល៉ោះហើយនាយគុចក៏ ចុះទៅក្រោមបាត់ទៅទុកឱ្យនាយយើងដេកក្រៀមអាចម៍ភ្នែកម្នាក់ឯងនៅលើសណ្ឋាគារ ។

ប្រហែលជាម៉ោង១២ថ្ងៃត្រង់ នាយគុច ចុះទៅខាងក្រោមក៏មិនទាន់ឃើញត្រឡប់មកវិញ ។ នាយព្រីលភ្ញាក់ម្ដងទៀតខំប្រឹងទប់អាត្មាក្រោកពីដេកទាំងពិបាក ។ ដើរទៅលុបមុខ សិតសក់រួចក៏មកអង្គុយចាំមើលផ្លូវនាយគុចនៅមាត់ទ្វារ ។ ភាពដ៏អស្ចារ្យកាល ពីយប់មិញនៅកន្ត្រាក់អារម្មណ៍មិនទាន់ភ្លេច នាយនឹកឃើញដល់រឿងនេះឡើងសម្បុរគីង្គក់ព្រឺព្រួចសារជាថ្មី ។

ចាំបាត់ ! ចាំបាច់ ! មិនឃើញនាយគុចត្រឡប់មកវិញ

នាយព្រីលនឹកអផ្សុក ណាដូចជាឃ្លានបាយផង ក៏ដើរទៅយកកាបូបប្រាក់រាប់ចំនួនមើល តើសល់ប៉ុន្មានអស់ប៉ុន្មាន ? លូករាវក្នុងហោប៉ៅសព្វអស់ ស្រាប់តែបាត់កាបូប បែរទៅមើលនាលិកាលើក្បាលគ្រែក៏បាត់ទៀត នាយព្រីលត្រជាក់ខ្លួន ធ្លាក់ថ្លើមក្ដុកដឹងថាអាអ្នកលេងគុចសម្លាញ់រួមស្រុកវាវ៉ៃធហើយ ។ ពេលនេះ សេចក្ដីសប្បាយរីករាយទាំងប៉ុន្មានអន្តរធានចេញពីខ្លួននាយព្រីលអស់រលីងគ្មានសល់ នាយចេះនឹកស្រុក, ឪពុកម្ដាយ, គូសង្សារ ហើយក៏នឹកបន្ទោសខ្លួនឯងមិនគួរណាប្រហែសឱ្យនាយគុចលួចប្រាក់បានដូច្នេះ ។

ចៅមាណពក្បាលទំពែក អង្គុយសំរក់ទឹកភ្នែកតក់ៗ ឧទានតិចៗចេញមកទាំងអស់សង្ឃឹម :



-អាគុចអើយអាគុច ... ! អាមិនគួរដាច់ចិត្តលួចលុយអញសោះ អញខំចាំវធឹកស៊ីស្រីញីប៉ុណ្ណឹងហើយ ឯងនៅមិនអាណិតអញទៀតឯងលួចលុយអញគ្មានបន្សល់អីតិចតួច សូម្បីតែអាក្រដាសចាយមិនកើតក៏ឯងយកដែរ ឱពុទ្ធោៗអើយ ... នេះហើយកម្មផងខ្ញុំ ... ម៉ែ ! ឪ ! កូននឹកម៉ែនឹកឪណាស់ តែទៅស្រុកវិញយ៉ាង ម៉េចនឹងរួច បើគ្មានលុយមួយកាក់ឥចឹង ... អូនធឿន ... ម្ល៉េះសមអូនមើលផ្លូវបងយ៉ាងណាទៅ ... បងនៅចាំរូបអូនជានិច្ច តែ ... បងគ្មានលុយជិះឡានទៅស្រុកវិញទេ ប្រហែលជាដាច់ពោះស្លាប់នៅស្រុកគេហើយអូន ...

នាយព្រីលកំពុងតែអង្គុយយំសោកាពិលាបក៏ឮសូរគោះទ្វារ :

-តុក ! តុក ! តុក ! ...

នាយព្រីល យកដៃជូតទឹកភ្នែក ក្រោកទៅបើកទ្វារអររខិបរខុបស្មានថាប្រហែលជានាយគុចត្រឡប់មក តែ ... ខុសស្រឡះអ្នកដែលចូលមកមិនមែននាយគុចទេ គឺជាបោយបំរើសណ្ឋាគារទេវិញ:

-អាលោក ! អា ... លោកមោនៅជិតឡប់ង៉ៃហើយ អាសៃហ៊ូអីឱ្យសុំគិតលុយមួយឡងហា ! ទីងអស់ ...

បោយរាប់ក្រដាសគិតប្រាក់ឈ្នួលប្រចាំថ្ងៃមួយសន្ទុះ ក៏ និយាយថា :

-ទឹងអស់ វាចាំបីងៃ មួយពាន់បីរយសាមសិបពីររៀល !

នាយព្រីលគ្រាន់តែឮចោយប្រាប់ថានៅខ្វះថ្លៃឈ្នួលបន្ទប់ដេក ជាងមួយពាន់រៀល ក៏ស្រែកយំខ្លាំងៗ ដូចក្មួនក្មេងឱនទៅក្រាបសំពះបាទជើងចោយសុំសេចក្ដីអនុគ្រោះ :

-ឱ ! អាហៀអើយ ... សូមអាណិតមេត្តាកុំយកឈ្នួលបន្ទប់អីខ្ញុំឥឡូវនេះគ្មានប្រាក់មួយសេនទេ អាពួកម៉ាក់ខ្ញុំវាលួចអស់ទៅហើយ ខ្ញុំរកតែ៧០រៀលជិះឡានត្រឡប់ទៅស្រុកវិញក៏គ្មានផង ...

-មីងបាងទេ ! មីងបាងទេ ! ឃាមមីងឡឹងទេ ចាំអាសៃហ្វូអីមោអ៊ីយាយមួយអ៊ីទៅ !

ថាហើយចោយសណ្ឋាគារក៏រត់ប្រញាប់ទៅប្រាប់ស្មៀនប្រចាំសណ្ឋាគារ ។

មួយសន្ទុះក្រោយមក ចោយអំបាញ់មិញក៏ត្រឡប់មក បន្ទប់នាយព្រីលវិញ នាំទាំងស្មៀនសណ្ឋាគារនិងភ្នាក់ងារប៉ូលិសក្រុងម្នាក់មកជាមួយផង ។

-គិតយ៉ាងម៉េចទៅរឿងឈ្នួលបន្ទប់ដេក មានលុយឱ្យខ្ញុំទេ ? ស្មៀនសណ្ឋាគារ សួរទៅនាយព្រីល ។

-ប្របាទ ! អត់ទេលោកថៅកែ ... សូមលោកថៅកែអាណិត



ជួយស្រោចស្រង់សត្វលង់ទឹកផង

នាយព្រីលឆ្លើយព្រមទាំងលើកដៃសំពះស្មៀន :

-អត់យ៉ាងម៉េចកើត ! ( ស្មៀនសម្លុត ) ពីយប់មិញខ្ញុំឃើញនាំស្រីមកដេកប្រាំមួយប្រាំពីរនាក់ ក៏ចេះមានលុយឱ្យ ត្រង់ឈ្នួលបន្ទប់ខ្ញុំម្ដេចក៏ឆ្លើយថាអត់ ! បើថាអត់មែនខ្ញុំឱ្យប៉ូលិសនាំទៅបកឥឡូវហ្នឹង !

ម្ដងនេះ នាយព្រីលកាន់តែភ័យមុខស្លាំង ដៃជើងញ័រទ្រើតៗដូចមាន់ធ្លាក់ទឹកព្រឹកព្រហាម :

-លុយខ្ញុំកាលមកពីស្រែកមានលោក តែព្រឹកមិញនេះពួកម៉ាកខ្ញុំវាលួចអស់ទៅ សូមលោកអាណិតមេត្តាខ្ញុំផង ...

-មិនបានទេ ! បើអ្នកឯងគ្មានលុយឱ្យខ្ញុំខ្ញុំត្រូវតែប្ដឹងអ្នកឯង ចង់ដោះស្រាយយ៉ាងម៉េចៗ ទៅដោះស្រាយមុខលោកគុម្មិស៊ែរវងស្នងការដ្ឋានទៅ

ស្មៀននិយាយជាមួយនាយព្រីលរួចហើយ ក៏បែរទៅនិយាយជាមួយភ្នាក់ងារប៉ូលិស :

-ឥឡូវខ្ញុំសូមប្ដឹងសែហ្វពីម្នាក់នេះក្នុងបទជួលបន្ទប់សណ្ឋាគារខ្ញុំដេកហើយគ្មានលុយបង់ សូមសែហ្វអញ្ជើញនាំខ្លួនយកទៅចុះ ។

បន្ទាប់មកនាយព្រីលក៏ត្រូវភ្នាក់ងារប៉ូលិសចាប់ខ្លួននាំយកទៅ

ស្នងការដ្ឋាន ។

.............................................................

លោកនាយស្នងការដ្ឋាន បានសាកសួរចម្លើយកត់ហេតុពីនាយព្រីលសព្វគ្រប់ ដោយយល់ឃើញថានាយព្រីលជាមនុស្សសុចរិតស្លូតត្រង់ ល្ងង់ខ្លៅមិនដែលមកភ្នំពេញ ហើយត្រូវគេលួចប្រាក់អស់មែន។ លោកនាយស្នងការអនុញ្ញាតឱ្យនាយព្រីលរួចទុក្ខទោស ។ ប្រាក់ឈ្នួលបន្ទប់សណ្ឋាគារជាងមួយពាន់រៀលលោកចេញឱ្យគ្រប់ចំនួន ហើយឱ្យនាយព្រីល២០០រៀលក្រៅទៀត ធ្វើសោហ៊ុយត្រឡប់ទៅស្រែវិញ ។

-នែ ! ថ្ងៃក្រោយបើអ្នកមកលេងភ្នំពេញ យើងមិនស្គាល់ទីក្រុងច្បាស់ ត្រូវរកអ្នកណាជាទីទំនុកចិត្តជូនមក កុំចេះតែជឿតាមមនុស្សបោកប្រាស់ឰទេ កុំស៊ីជោរឆ្កួតនឹងស្រីសំផឹងទៀតឱ្យសោះ អ្នកឯងជាប់បកពីព្រោះអី ? គឺពីព្រោះតែសេពគប់មិត្តអាក្រក់ ឈ្លក់វង្វេងនឹងស្រីសំផឹង ថ្ងៃក្រោយសូមកុំឱ្យលង់ខ្លួនខ្វះថ្លៃឡានឥចឹងទៀត ណាស់ហើយ ! អញ្ជើញទៅចុះ

-ប្របាទ ! ប្របាទមិនបំភ្លេចគុណព្រះតេជគុណអស់មួយជីវិត

នាយព្រីលចេញពីស្នងការដ្ឋាន ដើរដំរង់ទៅបេនឡានរករថយន្តទៅស្រែវិញជាបន្ទាន់ក្នុងថ្ងៃនោះ ។



~៦~

## ក្រមុំខ្មាវក កម្លោះស្លឈាម

ចាំបាត់យូរថ្ងៃមិនឃើញមក ចិត្តស្រីនឹកភ្នកឃ្លានស្នេហា
ចំលើជើងបោកប៉ុនរ៉ោហារ ស្រីឆ្កួតតណ្ហាចុះតាមភ្លាម ។
អានោះរៀបរាប់នឹងចេញយក្ស ឪម៉ែគេភ្ញាក់ស្រែកគំរាម
នាយព្រីលដឹងរឿងស្ទើរក្អួតឈាម ឡើងដើមព្រីងភ្លាមប្រុងចងក

សូមអស់លោកអ្នកអានជាទីគោរព បែរជួងចក្ខុត្រឡែកមកមើលឃុំព្រៃស្វាយ ឯស្រុកស្រែម្តងវិញ ។ មីងព្រាបបាត់ដំណឹងកូនកម្លោះយូរក៏កើតក្តីព្រួយបារម្ភ គាត់អង្គុយមិនសុខ ដើរមិនស្រួលក្រវល់ក្រវាយក្នុងចិត្ត ម្ង៉ៃៗ អង្គុយចាំមើលជើងឡាន ភ្នំពេញចង់ផ្សាភ្នែក ។

ចាំបាត់ ! ចាំបាត់ ! ... បីថ្ងៃ, បួនថ្ងៃ, ប្រាំថ្ងៃ, ប្រាំមួយថ្ងៃនៅតែមិនឃើញស្រមោលកូនត្រឡប់មក មីងព្រាបក៏អង្គុយនិយាយពិគ្រោះជាមួយពូព្រើលថា :

-ពុកវាអើយ ... ! អាព្រីលកូនយើងទៅភ្នំពេញម្តេចក៏ក្រមកម្ល៉េះ ខ្ញុំចេះតែនឹកភ័យៗ ខ្លាចក្រែងវាវង្វេងវង្វាន់ដាច់ពោះ ស្លាប់ទេពីព្រោះ

ខ្ញុំសួរអ្នកគេធ្លាប់ទៅ គេថាភ្នំពេញធំណាស់ ដើរលេងបីបួនខែមិនទាន់សព្វកន្លែងផងណាមួយថ្ងៃរៀបការក៏កាន់ តែខិតចូលមកជិតវរៗ វាមកមិនទាន់អីស្លាប់ខ្ញុំហើយមួយពេលនេះ ។

-ហ៊ី ! ពិបាកណាស់ ... (ពូព្រើលដកដង្ហើមធំជួយព្រួយភរិយា) អញកាត់មិនបានស្មានមិនយល់ទេ រឿងអាព្រើលនេះ ! ហាមហើយ ហាមទៀត ទៀតហើយទៀត ហាមថាកុំឱ្យវាទៅភ្នំ ពេញ បេះតែមិនជឿអញ ដល់បាត់ដំណឹងក៏នាំគ្នាកើតទុក្ខដូច្នេះឯង ។

ពូព្រើលនិយាយរួចមួរបារីស្លឹកសង្កែជក់បង្ហុយផ្សែងទ្រលោមទៅលើអាកាស ហាក់ដូចជាកំពុងគិតពីរឿងអ្វីម៉្យាង ។ មួយសន្ទុះធំក្រោយមកទើបពូគាត់និយាយថា :

-បើតាមគំនិតអញយល់ អាព្រើលវាមិនមែនវង្វេងវង្វាន់ទេ អានេះបែបដើររកទិញរូបថតបង្រៀនវិធីស្នេហាមិនទាន់បានហើយមើលទៅ ចាំមើលវាពីរបីថ្ងៃទៀតមើល៍ ! បើវានៅតែបាត់ស្រមោល ចាំអញឡើងឡានទៅភ្នំពេញតាមរកវា !

-ណាស់ហើយកុំនិយាយ ! (មីងព្រាបរាដៃ) ខ្លួនឯងមិនស្គាល់ភ្នំពេញបែរមុខទៅខាងណាផង សង្ហាចង់ទៅតាមកូន តិចពិបាកចោលឆ្អឹងស្រុកគេឱ្យខ្ញុំមេម៉ាយទៅ !



-យ៉ ! ឯងក៏មើលងាយអញខ្លាំងដៃម្ល៉េះ ! ស្មានតែអញហ្នឹងល្ងង់គ្រប់ដប់មិនដែលស្គាល់ភ្នំពេញដូចឯងសោះឬ ? អញប្រាប់ឱ្យដឹង ! កាលអញនៅពីក្មេងអញធ្លាប់ទៅតាមលោកម្ដងដែរ ទើបនឹងខានជាងសែសិបឆ្នាំទេតើ ហា ! ហា ! ហា !

ពូព្រើលថាហើយក៏សើចបន្ទូរអារម្មណ៍ ។

មីងព្រាប នឹកខឹងនឹងសំដីនិយាយមែនលាយលេង គាត់បែរមុខចេញពីប្ដី សម្លឹងមើលទៅលើមេឃ លើកដៃបន្ទូលលើក្បាលអធិដ្ឋានខ្លាំងៗថា :

-ឱ ! គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះធរកម្មាដែលមានមហិទ្ធិឫទ្ធិខ្លាំងក្លាលើទ្វីបលោកទាំងបួនអើយ ... ! សូមព្រះអង្គអាណិតមេត្តា ករុណា ប្រណី ដល់កូនខ្ញុំម្ចាស់ សូមឱ្យវាធ្វើដំណើរទៅទីក្រុងម្ដងនេះ បានជួបភពប្រសប់តែនឹងជោគលាភ ចង់រកអ្វីប្រាថ្នាអ្វីឱ្យបានដូចសេចក្ដីប៉ុនប៉ង សត្រូវមកពីមុខរលាយ មកពីក្រោយរលត់ កុំបីមានជម្ងឺដំកាត់ឬគ្រោះកាចដោយប្រការណាមួយ មកពារធាលើខ្លួនប្រាណវាបានឡើយ ...

ពោលចប់ អ្នកមីងឱនសំពះមេឃបីដង បែរមកសម្លក់ពូព្រើលបន្តិច ទើបក្រោកក្រេសដើរចូលទៅក្នុងផ្ទះបាយដណ្ដាំស្ល ទុកឱ្យពូយើង

អង្គុយបៀមបារីស្លឹកសង្កែបង្ហុយផ្សែងខ្មោលៗទៅ លើអាកាសតែឯកឯង។

រាត្រីនេះឃុំព្រៃស្វាយស្ថិតនៅក្នុងសភាពស្ងាត់ជ្រៀប ។ ធាតុអាកាសត្រជាក់គ្របដណ្ដប់ពាសពេញក្រឡាប្រថពី ខ្យល់ជំនោរពីទិសឦសានបក់បោកមកមិនដាច់វយៈ ។ មនុស្សម្នាសម្ងំពួនរងារតត្រុននៅក្នុងផ្ទះ បង្កប់នូវសេចក្ដីស្រួលស្រើបព្រឺព្រួចរៀងរាល់អាត្មា ។

នាងធឿនយប់នេះដេកមិនលក់ ក្នុងទ្រូងតឹងតែងក្ដៅក្រហាយរកអធិប្បាយមិនត្រូវ ម្ដងងាកមុខទៅឆ្វេង ម្ដងងាកមុខ ទៅស្ដាំបះលាន់ឮសូរប្រូស ! ប្រាស់ ! ពេញតែលើគ្រែ ។ នាងនៅចាំច្បាស់មិនទាន់ភ្លេចពាក្យនាយព្រីលសូមលានាងទៅ ភ្នំពេញទិញឥវ៉ាន់ការបីថ្ងៃ ឥឡូវហួសកំណត់ច្រើនទិវាទៅហើយ ក៏នៅតែមិនទាន់លេចមុខប្រុសធោមយង់មកទៀត ។ ថ្ងៃអាពាហ៍ពិពាហ៍ក៏កាន់តែខិតចូលមកជិត បើដល់ថ្ងៃការនាយព្រីលមិនទាន់មក តើឱ្យនាងទៅអង្គុយផ្ទឹមការជាមួយ អ្នកណាទៅ? ឱ្យពន្យាពេលអាក់ខានសិនឬ ? អូ ! មិនបានទេ ! ភ្លើងស្នេហ៍កំពុងឆាបឆេះដូចគេដុតភ្លើងព្រៃយកអណ្ដើកដូច្នេះ ហ៊ានតែខកខានមិនបានការថ្ងៃ១៣កើតខែកត្ដិកខាងមុខនេះ មុខជាប្រេះបេះដូងចេញឈាមហៀរកខ្វាក់ហើយ ។



នាងធឿន បើកបង្អួចគន់មើលទៅព្រះចន្ទនាថ្ងៃ១០ កើត ពន្លឺឆ្ពុះចាំងមកក្នុងបន្ទប់ភ្លឺព្រាលៗ ធ្វើឱ្យនាងបានសប្បាយរសាយពីទុក្ខព្រួយបន្តិច។ ស្រស់ស្រីសម្លឹងមើលទៅដើមពោធិ៍ក្នុងវង្វង់ព្រះចន្ទ ហើយក៏នឹកទៅដល់អនុស្សាវរីយ៍ស្គាល់គ្នាគ្រាដំបូងនៅក្រោមដើមព្រីង ។ នាងរបូតមាត់តិចៗចេញមកថា :

-ខែអើយៗ អើយខែ ... ! ម្ដេចក៏ខែចាំមានដើមពោធិ៍នៅវង្វង់ចំកណ្ដាលធ្វើអ្វី ? ឱ ... ! នេះប្រហែលជាខែសើចចំអកឡកឡឺយដាក់ខ្ញុំ ដោយដឹងថាខ្ញុំធ្លាប់អង្គុយសារសងជាមួយបងព្រីលហើយមើលទៅ ... !

នាងធឿនឈប់ស្ងៀមបន្តិច បង្វិលខ្លួនបង្អួតនឹងរស្មីចន្ទ្រា ពើងទ្រូងទៅមុខ យកដៃរលាស់សក់ជូនសើច ជូនធ្វើមុខមាំដូចខឹងសម្បាររួចពីហ្នឹងក៏ដើររាំក្បាច់ពត់ពែនពេញបន្ទប់ ។ ពុំមាននឹកខ្លាចក្រែងអ្នកណាម្នាក់លបឃើញកាយវិការវិកលចរិកនេះឡើយ ។

នៅក្រោមដើមក្រខុបក្បែរបន្ទប់នាងធឿនដេក ស្រមោលខ្មៅស្ទុងមួយសម្ងំពួនលួចលបមើលកាយវិការនាងធឿនយ៉ាងយកចិត្តទុកដាក់អស់រយៈពេលជាច្រើនម៉ោងមកហើយ ។ នាងធឿនពុំបានដឹងខ្លួនក៏តាំងបន្តសំដីទៀត :

-ខ្យល់ខែកត្តិកម្ដេចក៏ត្រជាក់ជាងសព្វខែម្ល៉េះ ? អូ ! យ៉ាងនេះហើយតើ ... បានជាចាស់ៗគាត់ដឹងចិត្ត គាត់រៀបការទុកដាក់កូនចៅតែខែកត្តិក ពីព្រោះខែនេះវាត្រជាក់គួរឱ្យព្រឺព្រួច គួចចិត្តស្នេហាមែន ... អ្នកតាកក្រហមអើយ ... សូមឱ្យបងព្រីលឆាប់វិលមកវិញមក ! នៅតែបីថ្ងៃទៀតទេ ដល់ថ្ងៃចូលរោងការ បើអ្នកតាជួយខ្ញុំបាន ខ្ញុំនឹងថ្វាយក្បាលជ្រូកមួយឱ្យសេពសោយ ... បើបងព្រីលមកមិនទាន់ទេ ខ្ញុំមិនដឹងបានអ្នកណាមករៀបការជំនួស មុខតែបោលចោលស្រុក រត់តាមប្រុសដទៃហើយ ... ខ្ញុំចង់បានប្ដីណាស់ ពេលយប់យន់ទន់ត្រជាក់ដូច្នេះធ្វើម្ដេចនឹងមាន ប្រុសប្រាណឯណាគេមកលួងលោមថ្នាក់ថ្នមខ្ញុំទៅហ្ន៎ ...

នាងធឿនទើបនិយាយផុតមាត់ សម្លេងបុរសចម្លែកឈរក្រោយដើមក្រខុបក៏សងវាចាមកនាងវិញតាមសសៃខ្យល់ឮរវើយៗថា:

-ឱ ! កែវឆវីនារីរតន៍ បងឈរស្ដាប់មាត់ស្រីយូរហើយ លុះដឹងចិត្តជាក់ទើបហ៊ានឆ្លើយ ធឿនអើយចុះមករកបងវ៉ា...

នាងធឿនភ្ញាក់ព្រើតដូចគេកន្ត្រាក់ នឹកអៀនអន់តាមនិស្ស័យស្រីក្រមុំ តែចិត្តមួយមកនឹកឃើញថាមានតែពីរនាក់ ហើយយប់ស្ងាត់ផងនាងក៏អន់ខ្មាស់ ក្លែងវាចាសួរទៅវិញថា :

-អ្នកឯងជាមនុស្សដូចគេឯង ឬជាខ្មោចព្រាយបីសាច ? បាន



ជាក្លាហានហ៊ានឆ្លើយឆ្លងសងសំដីជាមួយកូនក្រមុំគេកណ្ដាលរាត្រីស្ងាត់ដូច្នេះ !

-បងជាមនុស្សទេអូនពិសី នាងកុំខ្លាចអីចុះដីមក
បងដឹងថាអូនកើតទុក្ខសោក ទើបបងស្ទាត់រកកែវជីវ៉ា
បងជួយថ្នាក់ថ្នមលោមមាសចិត្ត ព្រោះដឹងថាអូនជិតរៀបការ
ម្ដេចឡើយចាំបាច់សួរតវ៉ា ឬមួយកនិដ្ឋាមិនទុកចិត្ត ។
អាព្រីលនិងបងស្គាល់គ្នាជាក់ ធ្លាប់រៀនរួមថ្នាក់យ៉ាងជិតស្និទ្ធ
វាផ្ដាំឱ្យបងជួយអាណិត ឱ្យជួយបង្ហាត់ក្បួនស្នេហា ...

-អ៊ុំ ! បងហ្នឹងជាមិត្តភ័ក្ត្រនឹងបងព្រីលឬ ?

-ត្រូវហើយអូន ! បងជាមិត្តនិងអាព្រីល !

-ចុះបងឈ្មោះអ្វីទៅ ប្រាប់ខ្ញុំឱ្យស្គាល់ផងបានទេ !

-មិនចាំបាច់សួរទេពៅពន្លក ឱ្យតែអូនចុះមកប្រាកដជាស្គាល់ហើយ !

នាងធឿនឮដូច្នោះ លាត់សំពត់ចងក្បិនយ៉ាងតឹងសំរូតចុះមកសំដៅទៅរកបុរសរាត្រី នឹកកោតសរសើរតែក្នុងចិត្តថា : អ្នកណាគេនេះអេះ ? ក៏ប៉ិនទាំងវោហារកំណាព្យកាព្យឃ្លោងម្ល៉េះ ? សំដីសំដៅទៀតសោតក៏ផ្អែមល្ហែម ប្រហែលជាមុខមាត់ស្អាតបាតណាស់ហើយមើល

ទៅ ។

នាងធឿនដើរទៅដល់ជិតក៏ភ្ញាក់ព្រើត ដោយស្គាល់ជាក់ជាកូនប្រសាមេស្រុកគាំ ។

-យី ៗ ហ្មងសនទេឬ ?

-ត្រូវហើយ ! កុំមាត់ខ្លាំងអូន ប្រាកដជាបងហើយកុំសង្ស័យទៀត ។

-បងឯងមកឈរធ្វើអីយប់ថ្មើរហ្នឹង ?

-បងមករកអូនតាមបណ្ដាំអាព្រើល !

អន្ទិតសននិយាយហើយក៏ទាញដៃនាងធឿនឱ្យអង្គុយចុះ ផ្អែកនឹងគល់ក្រខុប តែនាងបេះដៃចេញ ប្រត់ចង្កេះសួរទៅវិញថា :

-បងព្រើល ! ... គាត់ផ្ដាំផ្ញើនឹងបងសនឯងយ៉ាងម៉េចខ្លះ និយាយប្រាប់ខ្ញុំមកមើល ?

-វាផ្ដាំនឹងបងថា បើពេលណាវាមិននៅ ឱ្យបងមកជួយថែរក្សាអូនផង ហើយវានិយាយទៀតថា ម៉ែវាក៏ដូចម៉ែបង ប្រពន្ធវាក៏ដូចជាប្រពន្ធបងដែរ .... !

នាងធឿនហេតុតែជាស្រីក្រមុំល្ងង់ដប់គត់ ក៏លង់ចិត្តជឿតាមសំដីអន្ទិតសនស្លុង សមពេលនេះនាងកំពុងត្រូវការរកគូនែបនិត្យផ្ចិតឱ៊ា



ស្រាប់ផង ក៏ពុំបាននឹកសង្ស័យឬនឹកខ្មាស់អៀនថាខ្លួនជាស្រីក្រមុំព្រហ្មចារីយ៍ មិនគួរណាចុះមកជួបប្រុសឈ្មោលកណ្ដាលអាធ្រាត្រស្ងាត់ឡើយ។

អន្ទិតសនបានដៃ ឃើញនាងធឿននៅស្ងៀមក៏ចាប់ឱបរិតផ្ដួលប្រាណទាំងជំហរទៅលើវាលស្មៅក្បែរគុលក្រខុប នឹកក្នុងចិត្តថា ម្ដងនេះមុខជាបានសងសឹកនឹងនាយព្រើលវិញហើយ ។

-អូនធឿនអ៊ំា ... !

-ចំា ... បងសន ... !

-អូនឯងជាតិនេះអភ័ព្វណាស់ បានប៉ះលើប្ដីក្បាលទំពែក មនុស្សយ៉ាងអាព្រើលមិនគួរណាអូនទៅស្រឡាញ់វាទេ ...

នាងធឿនភ្លើងកាមរាគៈកំពុងឆេះក្នុងទ្រូងក្ដៅគគុក ក៏បង្អើបមាត់សួរទៅនាយសនទាំងភ្នែកមមីរដូចមនុស្សស្រវឹងកញ្ឆាថា :

-ចុះមនុស្សរបៀបណាទៅដែលអូនគួរស្រឡាញ់ ... ?

-នៅជិតៗអូនហើយតើ ចាំបាច់ឱ្យបងប្រាប់ចំដល់ណាទៀត ។

-អូ ! បងហ្នឹងឬ ? (នាងធឿនធ្វើជាភ្ញាក់) ខ្ញុំមិនហ៊ានស្រឡាញ់ទេ ខ្ញុំជិតរៀបការហើយ ណាមួយបងក៏មានប្រពន្ធ លោតែមីរ៉នដឹងខ្ញុំលួចប្ដីវា វាមិនលីពូថៅទាំងកណ្ដាលថ្ងៃត្រង់មកពុះចំ ពាក់កណ្ដាលដើម

ទ្រូងខ្ញុំទៅហើយឬ ?

អន្ទិតសនសើចតិចៗ លូកដៃទៅច្របាច់សុដន់នាងធឿនបណ្ដាលឱ្យនាងឡើងសម្បុរគីង្គក់ព្រឺខ្នាកៗមួយរំពេច :

-អូនឯងនៅខ្លាចដល់ណាទៀត (អន្ទិតសននិយាយ) អាព្រីលប្រហែលជាវាឈ្លក់វង្វេងស្រីភ្នំពេញ ហើយបានជាបាត់ដំណឹង ! អូនឯងទ្រាំចាំវាប្រយ័ត្នវងារបេះដូងកកឈាមស្លាប់ណា ... !

-ចា៎ះ ... ! អូនជឿបងហើយ តែសូមបងប្រាប់មីរ៉ែនកុំឱ្យវាវាយខ្ញុំណា៎ គឺខ្ញុំការជាមួយបងព្រីលផង ស្រឡាញ់បងសនឯងផងឥចឹងស្រួលទេ ? ពីព្រោះវាត្រូវនឹងបណ្ដាំបងព្រីលគាត់ផ្ដាំបងថា ម៉ែគាត់ដូចម៉ែបង ! ប្រពន្ធគាត់ដូចប្រពន្ធបង ដូច្នេះខ្ញុំសង្សារបងដែរ កាលណាបងព្រីលធ្វើបាបខ្ញុំៗ ទៅជាមួយបង ហើយបើបងសនឯងធ្វើបាបខ្ញុំៗមកនៅជាមួយបងព្រីលវិញ ។

អន្ទិតសននឹកពេញចិត្តនឹងសំដីល្ងង់ខ្លៅរបស់នាងធឿន គេគិតថាពេលនេះជាឱកាសល្អហើយ ដែលគេគួរតែបង្ហួរម៉ាក្សជាមួយនាងឱ្យទាល់តែសំរេច ដើម្បីជាកិច្ចផ្ដន្ទាទោសចំពោះអំពើដែលនាយព្រីលចិត្តធំថ្លើមពាសមេឃ ហ៊ានលបឡើងផ្ទះទាំងយប់ ទៅមើលខ្លួនកំពុងបង្រៀនវិធីស្នេហា ដល់ប្រពន្ធ ។



អន្ទិសនចិត្តពាល លិទ្ធមាត់លិទ្ធកបោលសំរុកទាំងបិទភ្នែកជិតថើបក្រញីញក់ញីលើខ្លួនប្រាណនាងធឿនគ្មានត្រាប្រណី រីឯដៃខំប្រឡេះឡេវអាវយ៉ាងប្រញាប់ ។ នាងធឿនមិនធ្លាប់អ្នកណាធ្វើរបៀបនេះមកពីមុន ក៏បេះនាយសនចេញ ក្រោកអង្គុយឱបក្បាលជង្គង់ផ្ទប់នឹងដើមទ្រូងជាប់ :

-ឈប់សិនបងសន ! បងឯងគិតធ្វើអីខ្ញុំហ្នឹង ... !

-ដោះអាវចេញទៅអូន ... !

-ទេ ! ខ្ញុំមិនដោះទេ ! វងារចង់ស្លាប់ទៅហើយ ដោះធ្វើ អី ?

អន្ទិតសននឹកស្រងាកចិត្តកាលបើមិនបានសមបំណង ។ ឈប់ដកដង្ហើមឱ្យបាត់ហត់បន្តិច នាយពាលក៏ប្រឹងនិយាយលួងលោមទៀត :

-មនុស្សយើងកាលណាគេស្រឡាញ់គ្នាគេត្រូវតែដោះអាវចេញ ទើបសន្មត់ថាយើងចិត្តស្មោះត្រង់នឹងគ្នាណា៎អូន ...

នាងធឿនគ្រវីក្បាលមិនព្រម :

-ទេ ! ខ្ញុំមិនដោះអាវទេ ! វងាររណ្ដំថ្កាមយ៉ាងនេះសមតែពាក់អាវប៊ូនដប់ជាន់ គ្រលំភួយពីរបី ឱ្យដោះអាវចេញអស់រលីងបងឯងមិនចេះវងារទេឬ ?

អន្ទិតសនអស់ផ្លូវនឹងពន្យល់នាងធឿនឱ្យដោះអាវបាន អ្នកក៏នឹក

ឃើញមធ្យោបាយថ្មីមួយទៀតបំរុងនឹងចាប់ផ្ដើមអនុវត្តន៍ ស្រាប់តែ ! ...

-កាធឿន ! អើ ... កាធឿន ! យី ! ចុះកូននេះវាទៅឯណា...?

សម្លេងមីងឡឹកស្រែកប្រកួកមកទៀត ។

នាងធឿនភិតភ័យរកព្រលឹងព្រលះគ្មាន មិនដឹងគិតយ៉ាងណា ក៏ធ្វើជាប្រះខ្លួនដេកលក់ក្បែរគល់គ្រខុបនោះទៅ ទុកឱ្យពូញៀ មីងឡឹកស្រែកប្រកួកហៅស្អកកតែពីរនាក់ ។

មួយសន្ទុះមក ភ្លើងចន្លុះពីរដើមក៏ទ្រោលមកជិតកន្លែងនាងធឿនដេក ។ ពូញៀមីងឡឹក ឃើញជាក់ជាកូនត្រមុំគាត់ហើយក៏ម្នីម្នាចាប់អង្រួនឱ្យភ្ញាក់ ។

-នែ ! កាធឿន ! ម៉េចក៏ឯងមកដេកក្រោមដើមគ្រខុបទៅវិញ?

មីងឡឹកសួរ ។

នាងធឿនគ្រវីក្បាលធ្វើភ្នែកម៉ក់ៗ ស្ទាបហារមាត់មួយចង្អាម ដូចនៅមិនទាន់ស្វាងងងុយ បែរជាសួរបញ្ច្រាសស្រដីទៅម្ដាយវិញថា :

-ព្រឹកហើយឬម៉ែ ?

-អើ ! ហ្នឹងបានចំជាប្រាំពីរសន្ដាន អញសួរថាយ៉ាងម៉េចបានជាដេកនៅក្នុងបន្ទប់សុខៗ ប្រកាច់មកនៅឯណេះទៅវិញ ?

-អូ ! យី ! (នាងធឿនបើកភ្នែកធំៗ ធ្វើជាទើបនឹងភ្ញាក់ដឹងខ្លួន)



ខ្ញុំអត់ដឹងខ្លួនឯងថាមកដេកក្រោមដើមគ្រខុបហាល ខ្យល់សន្សើមឥចឹងទេម៉ែអើយ ... !

-ឥចឹងមានតែឯងដេកមមើល ?

-ចំា ! ប្រហែលហើយម៉ែ !

នាងធឿនឆ្លើយចាក់បណ្ដោយតាម ។

ពូញៀជឿឥតសង្ស័យ គាត់ប្រញាប់និយាយទៅកាន់ ប្រពន្ធថា:

-នាំវាទៅលើផ្ទះភ្លាមៗ ទៅ ! មនុស្សដេកមមើមមាយអត់ដឹងខ្លួនប្រាណឥចឹង ទាល់តែស្អែកយកទៅវត្តឱ្យលោកស្រោច ទឹកហើយអានេះពាក្យចាស់គេហៅថាបីសាចកន្ទង កាលអញនៅពីកម្លោះដូចវាម្ដងដែរ ! អញមមើស្រាតខោដើរកាត់ស្រែពីរ ស្រែបីទាល់តែខ្មោចពុកគាត់យកទៅស្រោចទឹកធ្វើខ្សែចង្កេះឱ្យពាក់ទើបបានបាត់ ! ...

-ហ៊ុ ... ! សព្វៗ ហើយកាធឿនអើយ កាធឿន ! ...

មីងឡឹករអ៊ូរទាំ ហើយក៏ដឹកដៃនាងធឿនដើរនាំមុខពូញៀឡើងទៅលើផ្ទះវិញ ។

ព្រឹកស្អែកឡើង ...

ខណៈដែលពូព្រើលមីងព្រាប កំពុងអង្គុយពិគ្រោះគ្នាពីរឿងបាត់ដំណឹងកូនកម្លោះនៅយ៉ានហាលខាងមុខផ្ទះ ក៏ស្រាប់តែលេចមុខនាយ

ព្រិលពើមមក ។

មីងព្រាបស្ទុះចុះពីលើផ្ទះទៅទទួលកូនត្រេកអរវរខិបវខុប តែគាត់មកនឹកចម្លែកចិត្តត្រង់មុខនាយព្រិលមិនស្លូវស្រស់បស់ ហើយគ្មានឃើញកាន់កញ្ចិបកញ្ចប់ជាប់ដៃអ្វីមកបន្តិចបន្តួចសោះ ។ ឡើងអង្គុយលើផ្ទះស្រួលបួល មីងព្រាបក៏ចាប់ផ្តើមសាកសួរថា :

-ម្តេចក៏ទៅភ្នំពេញអីយូរថ្ងៃម្ល៉េះកូន ម្តាយខំចាំមើលផ្លូវឯងរាល់ថ្ងៃឡើងផ្សាភ្នែក ហើយម៉េចក៏មុខមាត់ក្រៀមក្រោះឥចឹង ? ឯងឈឺឬ? ឯណាឥវ៉ាន់ទិញមករៀបការ ?

នាយព្រិលមិនឆ្លើយតបនឹងសំនួរម្តាយ បែរជាស្រែកយំខ្លែងៗ ហៀរទឹកភ្នែកទឹកសម្បោរដូចកូនក្មេង ។ មីងព្រាបមិនដឹងរឿងហេតុឃើញកូនយំខុសទំនងក៏រិតតែភ័យបញ្ឈរភ្នែក ។ ពូព្រើលស្មារតីរឹងប្រញាប់សួរទៅកូនថា :

-រឿងហេតុអីបានជាឯងយំ ? និយាយប្រាប់អញឱ្យដឹងផងមើល ?

-បាទពុក !(នាយព្រិលនិយាយអណ្តឹតអណ្តក់) ខ្ញុំ ... ខ្ញុំ ...ចាញ់បោកអាគុចមួយបានស្រឡះ ... ! ទៅលេងភ្នំពេញវិះជាប់គុកខានឃើញមុខឪម៉ែ ... ខ្ញុំអត់លុយជិះឡានមកវិញទេ ... បើកុំបានលោក



គុម្មិស្សៀរឱ្យថ្លៃឡាន ប្រហែលជាដេកអត់បាយស្លាប់ស្រុកគេហើយពុកអើយ ...

-វាយ៉ាងម៉េចឥចឹង ! ក្រែងឯងទៅពីនេះយកប្រាក់មួយម៉ឺនទៅដែរអី !

ពូព្រើល សួរទៅកូនកម្លោះដោយងឿងឆ្ងល់ ។

នាយព្រិលលើកជាយអាវជូតទឹកភ្នែកឱ្យស្ងួត ហើយក៏និយាយរ៉ាយរាប់រឿងរ៉ាវប្រាប់ទៅឪពុក :

-កាលអាគុចវ៉ានាំខ្ញុំទៅដល់ភ្នំពេញ វាជួលបន្ទប់ផ្ទះសំណាក់មួយនៅក្បែរផ្សារថ្មីឱ្យខ្ញុំឈប់សំណាក់ ម៉្ងៃៗវានាំខ្ញុំដើរលេងគ្រប់ច្រកល្ហក វាបញ្ជោរខ្ញុំឱ្យប៉ាវវាស៊ីចាយដូចជាកូនមហាសេដ្ឋី មានល្ងាចមួយវាបង្អកស្រាខ្ញុំទាល់តែស្រវឹងលែងដឹងខុសត្រូវ វាឱ្យខ្ញុំទៅស្គាល់បនស្រីសំផឹង អំណាចស្រាធ្វើទុក្ខ ខ្ញុំក៏ជ្រុល ខ្លួនជាមួយពួកមីអស់នោះមួយយប់ទើសភ្ញីទៅ លុះព្រលឹមឡើង អាគុចលួចប្រាក់ខ្ញុំរត់បាត់លែងយល់ស្រមោល ម្ចាស់ផ្ទះសំណាក់មកទារថ្លៃបន្ទប់ ដល់ខ្ញុំឆ្លើយថាអត់ គេក៏ប្តឹងប៉ូលិសឱ្យចាប់ខ្ញុំទៅបក ទំរាំលោកគុម្មិស្សៀរសាកសួររកខុសត្រូវ ខ្ញុំជាប់ឃុំអស់កន្លះព្រឹក ដែលខ្ញុំមានលុយជិះឡានមកផ្ទះវិញនេះ គឺលោកឱ្យប្រាក់ខ្ញុំទេ នឹកៗទៅខ្ញុំឈឺចិត្តនឹងអាគុចបោកប្រាស់ ចង់តែលោតពីលើផ្ទះ

ឱ្យបាក់កស្លាប់ឥឡូវទេពុក ! ...

ពូព្រើលស្តាប់ពាក្យកូនបរិយាយរួចដកដង្ហើមធំ គ្រវីក្បាល នឹកផ្អែតចិត្ត :

-ហ៊ីប្រាក់ក៏បង់ចង់ក៏ដាច ! ឈប់កើតទុក្ខព្រួយទៅ កុំទៅគិតចង់សម្លាប់ខ្លួនអីណ៎ា ! អស់ប្រាក់មួយម៉ឺនរៀលទុកដូចជាម៉ែឯងគេចាញ់កន្ទុយលេខសៀមមួយចានទៅចុះ !

-នែ ! ឱ្យវាល្មមៗទៅលោកបងព្រើល ! កុំបាច់និយាយដាក់ផ្លែដាក់ផ្កាដៀមដាមមកដល់ខ្ញុំណ៎ា !

មីងព្រាបស្រែកគំហកឱ្យប្តី ដោយខឹងនិយាយរឿងកន្ទុយលេខ:

-រឿងកូនចៅធំប៉ុនភ្នំមិនគិតដោះស្រាយ ! បែរជាយករឿងឯងលេងកន្ទុយលេខពីឆ្នាំពោរកំពោរឯណាមកនិយាយទៅវិញ ត្រូវដឹងថាជញ្ជាំងមានត្រចៀកណ៎ា ! តិចពិបាកចូលគុកអស់ទាំងសំបុក ! ...

-ហា ! ហា ! ហា ! (ពូព្រើលសើច) ឥឡូវឯងចេះខ្លាចគុកច្រវាក់ដែរឬ ? បើឯងចេះតែរបៀបនេះប៉ុន្មានឆ្នាំមុន មិនមែនអាសេងលីវាជញ្ជូនប្រាក់ទៅធ្វើផ្ទះថ្មកំពស់ភ្នំសំពៅបាត់ដំបងបានទេ ណាស់ហើយឈប់និយាយទៀតទៅ ! អញថ្លង់ត្រចៀកណាស់

-អើ ! វាមកតែពីកញ្ចាស់ក្បាលឯងហ្នឹងនាំអញនិយាយមុន



អញឈប់ប្រព្រឹត្ត ឈប់នឹកនាមកយូរហើយតើ !

មីងព្រាបបើកភ្នែកក្រឡេតៗ ជជែកបែកពពុះមាត់មិនព្រមចុះចាញ់ប្តី ។

បរិយាកាស ស្ថិតនៅក្នុងសភាពស្ងប់ស្ងាត់មួយខណៈ បន្ទាប់មកពូព្រើលក៏ប្រែបទសន្ទនា និយាយទៅកាន់នាយព្រឹលថា :

-ទៅរកងូតទឹកងូតភក់ទៅកូន ! ឯងឈប់ព្រួយចិត្តទៀតណាអាណិតតែឪពុកផងទៅចុះ នៅពេលតែបីថ្ងៃទៀតដល់ថ្ងៃចូលរោងការហើយ ល្ងាចត្រជាក់បន្តិចល្មមទៅលេងផ្ទះមីនាងធឿនផង ឪពុកម្តាយគេ គេចាំមើលផ្លូវឯងសម្បើមណាស់ ... !

-បាទ ! ពុក ...

នាយព្រឹល ឆ្លើយរួចក៏កំពៀកបង្វិចខោអាវ ក្រោកដើរចូលទៅខាងក្នុងផ្ទះបាត់ទៅ ។

.............................................................

ល្ងាចត្រជាក់ ខ្យល់ធ្លាក់ពីទិសឧត្តរ បក់បោកផ្កាព្រៃឱ្យមានចលនារេរាំពត់ពេនដូចហ្វូងកិណ្ណរីលេងទឹកស្រះ ។

នៅគុម្ពោតព្រៃខាងលិចដើមព្រីងឯណោះ នាយព្រឹលនិង នាងធឿនកំពុងអង្គុយសាកសួរសុខទុក្ខគ្នាដោយសភាពស្ងប់ស្ងាត់ កន្លែងនេះ

ហើយជារមណីយដ្ឋានដែលអ្នកទាំងពីរផ្ដួចផ្ដើមផ្ញើពាក្យពេចន៍នឹងគ្នាគ្រាដំបូង ។

_បងព្រីលអ៊ំា ... បងទៅភ្នំពេញទិញអ្វីបានខ្លះ ហើយម្ដេចក៏យូរម្ល៉េះ អូនស្មានថាបងឈ្លក់វង្វេងស្រីទីក្រុង ភ្លេចកាធឿនស្រីស្រុកស្រែហើយទេតើ ... ?

នាងធឿននិយាយរួច ក៏ផ្ដេកក្បាលកើយភ្លៅប្រុសស្នេហ៍ដូចសព្វដង ។

_ហ៊ឺ ! (នាយព្រីលដកដង្ហើមធំ ) រឿងបងទៅភ្នំពេញ តែនឹកឃើញឡើងកាលណា ចង់តែចងកសម្លាប់ខ្លួនទេអូន បើអូនស្រឡាញ់បង សូមចិត្តកុំឱ្យបងនិយាយល្អជាង បងក្ដៅចិត្តណាស់ !

នាយព្រីល ភ្នែករលីងរលោងរកកលចង់យំ ឈប់ស្ងៀមបន្តិចយកខ្នងដៃជូតទឹកភ្នែកស្អាត ទើបនិយាយតទៅទៀត :

_ពិតមែនតែខ្លួនបងឃ្លាតចេញឆ្ងាយ តែចិត្តបងនៅចងចាំមកលើរូបអូនគ្រប់ដង្ហើមដកចេញចូល ! ក្នុងជាតិនេះបងគ្មានស្រឡាញ់ស្រីណាក្រៅពីអូនទេ ... តើអូនមាននឹកដល់បង ដូចជាបងនឹកអូនទេ ?

_ចំា ! ខ្ញុំនឹកបងដែរ ! កាលបងរៀបទៅភ្នំពេញ បងផ្ដាំឱ្យបងសនប្ដីមីរ៉ែនមកថែរក្សាខ្ញុំមែនទេ ?



_ថែរក្សាយ៉ាងម៉េច ! ហ៊ឺា !(នាយព្រីលសួរទៅសង្សារស្ទើរចង់ទៅជាស្រែក ) វាធ្វើអ្វីអូនឯងខ្លះ ? បងស្បថឱ្យងាប់ឪម៉ែបងទៅចុះ ! បងមិនដែលមានពាក្យផ្ដាំផ្ញើអីវាទេ ! មើល ! អូនឯងនិយាយប្រាប់បងឱ្យត្រង់មកមើល៍ ! វាធ្វើអីអូនឯងខ្លះ ? វរ៉ៗ ខ្មៅខ្ពក់ចាយបិណ្ឌជាបាយបាត្រអស់ទៅហើយក៏មិនដឹង ?

នាងធឿន ត្រូវនាយព្រីលសង្សកខ្លាំងក៏ស្លន់ភ័យ ស្រក់ទឹកភ្នែកញ័រមាត់រកនិយាយលែងរួច បង្កើនឱ្យនាយព្រីលកាន់តែសង្ស័យ ក្ដៅក្រហាយខ្លាំងទៅទៀត :

_អូនឯងនិយាយប្រាប់បងភ្លាមមក ! តើវាបានលួចប្លន់អ្វីពីអូនទៅខ្លះ ? អូនឯងនេះបានចំជាក្រមុំខ្វារក ! គ្រាន់តែជិតដល់ថ្ងៃរៀបការទ្រាំចាំឱ្យដល់សិនមិនបាន ! បងដឹងរឿងហើយ ! អាសនវាធ្វើហ្នឹងគឺចង់សងសឹកបង យើ ! អាសម្លាញ់កុំតែខ្លាចបែកការ កុំអីបានល្អមើលហើយអាភឿន !

និយាយចប់ នាយព្រីលក៏ក្រោកឈរលាស់ដៃអាវ តាំងឃុំគុនលោតបុកតោ ពេញគុម្ពោតព្រៃ ដោយកំហឹងក្រេវក្រោធមហិមា ។

រីឯនាងធឿន ព្រលឹងព្រលះចូលមកសន្ធិតក្នុងខ្លួនវិញសព្វគ្រប់ក៏និយាយប្រាប់ទៅនាយព្រីលថា :

-កុំអាលប្រឡោតខ្លាំងពេកបង ... ! ចាំស្ដាប់ពាក្យអូននិយាយប្រាប់សិន រឿងហេតុទាំងប៉ុន្មានគឺខុសមកពីអូន ហើយដែលអូនប្រព្រឹត្តខុសនេះទៀតក៏មកតែពីសេចក្ដីល្ងង់ខ្លៅ ...

-អើ ! អាឆ្កួតអាល្ងង់បងមិនដឹងទេ បងសូមសួរដោយខ្ញីថាវាបានធ្វើអីខ្លះ ?

-ចាំះ គាត់បានឱប !

-អែយូយ ! ស្លាប់អញហើយ ... !

នាយព្រីលភ្ញាក់មាត់ ប្រញាប់សួរបញ្ជាក់ថែម :

-ដល់ឱបហើយយ៉ាងម៉េចទៅទៀត

-ចា៎ ! គាត់ថើប ...

-វ៉ាស់ !!! អានេះបានចំកៅឌី ! តែប៉ុណ្ណោះស្រេចហើយ !

នាយព្រីលរលាស់ដៃចេញពីសង្សារ រត់សំដៅទៅឡើងដើមព្រីង យកក្រមាចងកខ្លួនឯងថ្កក់ជាប់នឹងបង្កាបមែកព្រីង បំរុងលោតសម្លាប់ខ្លួន ។

នាងធឿនឃើញដូច្នោះខ្លាចសង្សារស្លាប់ ភ័យមុខឡើងស្វាយ លើកដៃសំពះនាយព្រីលពីក្រោមដើមព្រីង និយាយអង្វរថា :

-បងព្រីលកុំទាន់លោត ! ចាំស្ដាប់ពាក្យអូនឱ្យចប់ចុង ចប់ដើម



សិន ! បងសនគាត់ថើបហើយគាត់ច្របាច់ដោះ ផុតពីច្របាច់ដោះទៅគ្មានអីទៀតទេ ពីព្រោះពេលនោះឪនិងម៉ែគាត់ភ្ញាក់ ស្រែករកអូន បងសនក៏បោលចូលព្រៃបាត់ទៅ !

នាយព្រីលឈប់ទ្រឹង ដៃកាន់ក្រមាទ្រង់គិតមួយសន្ទុះទើបហារមាត់សួរមកនាងធឿនថា :

-បើតចឹង ! ក្រៅពីថើប, ច្របាច់ដោះ, ប្រាកដជាគ្មានអ្វីលើសពីហ្នឹងពិតមែនឬ ?

-ចា៎ ! អត់ទេបង ... ! ឱ្យអូនស្បថដល់ណាក៏ហ៊ានដែរ ។

-អើ ! បើពិតដូចពាក្យថា អាហ្នឹងវានៅតែកុនបាន ឈប់ភ័យទៅបងមិនលោតទេ !

ថាហើយនាយព្រីលក៏សំរូតចុះពីលើមែកព្រីងមកដីវិញ ។

នាងធឿនអរស្ទុះទៅឱបនាយព្រីលញញឹមចេញមកទាំងទឹកភ្នែកនៅហូររហាម :

-រឿងកន្លងហួសមកហើយសូមបងកុំយកវាធ្វើជាអារម្មណ៍ ការអ្វីទាល់តែធ្វើខុសម្ដងទើបរកត្រូវឃើញ ឥឡូវយើងទៅផ្ទះវិញបង កុំឱ្យម៉ែគាត់ចាំមើលផ្លូវ ។

-ទៅក៏ទៅ ! តែឱ្យបងសុំថើបមួយខ្សឹតសិន !

-ហក ! ថើបទៅ ... !

នាងធឿនហុចថ្ពាល់ឱ្យនាយព្រឹលថើប ។ លុះថើបរួចហើយ ! អ្នកទាំងពីរក៏នាំគ្នាដើរមកផ្ទះវិញ បាត់ទុក្ខ បាត់ព្រួយតាំងពីពេលនោះ ។

បីថ្ងៃក្រោយមក ពិធីរៀបមង្គលការរវាងអ្នកកម្លោះព្រឹល និង នាងកញ្ញាធឿនក៏បានរៀបចំធ្វើឡើងយ៉ាងគគ្រឹកគគ្រេងអធឹកអធម។ ភ្ញៀវក្រមុំកម្លោះចាស់ទុំក្នុងស្រុក បានមកជូនសព្ទសាធុការពរដល់យុវស្វាមីភរិយានេះគ្រប់ៗគ្នា ។ អន្ទិតសនក៏ត្រូវគេអញ្ជើញមកក្នុងពិធីនេះដែរ តែហាក់ដូចជាមិនសូវរីករាយសប្បាយដូចភ្ញៀវឯទៀតៗសោះ ។

-ចប់-

អ្នកនិពន្ធ

ឋាក់-ឆៃហុក